# ព្រះវិហារវត្តពេជ្រមកុដ

វត្តពេជ្រមកុដ[1] ស្ថិតនៅត្រើយម្ខាងទន្លេចតុមុខ នៃទិសខាងកើតរាជធានីភ្នំពេញ ក្នុងឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្ដាល។ បើផ្អែកតាមឯកសារកម្រងប្រវត្តិវត្តនានាក្នុងខេត្តកណ្ដាលបញ្ជាក់ថា វត្តពេជ្រមកុដកកើតឡើងតាំងពីឆ្នាំ១៧៥៨ ហើយដើមឡើយគេហៅវត្តនេះថាវត្តលោកតាកុក។[2] បច្ចុប្បន្ននៅក្នុងបរិវេណវត្ត មានព្រះវិហារតូចមួយសម្រាប់ជាទីគោរពបូជារបស់ពុទ្ធបរិស័ទ ដែលគេអះអាងថាមានអាយុកាលជាង១០០ឆ្នាំហើយ (រូបលេខ១)។ ព្រះវិហារនេះសង់ពីបេតុងទាំងដំបូល និងផ្នែកផ្សេងទៀតស្រដៀងនឹងព្រះវិហារចាស់ស្ថិតក្នុងវត្តទឹកថ្លា រាជធានីភ្នំពេញ ដែលកសាងក្នុងឆ្នាំ១៩២៨។[3]



*រូបលេខ១ ព្រះវិហារវត្តពេជ្រមកុដមើលពីជ្រុងនិរតី*

---

[1] ចំពោះឈ្មោះវត្តនេះ អ្នកខ្លះក៏ហៅថា "វត្តមកុដពេជ្រ" ដែរ។

[2] ឯកសាររៀបរៀងដោយអាចារ្យ គណៈកម្មការតាមវត្តនីមួយៗ តាមការស្នើសុំពីក្រសួងធម្មការនិងសាសនាក្នុងឆ្នាំ២០១៣។

[3] សូមអានបន្ថែម "ស្ដាបត្យកម្មបុរាណស្ថិតក្នុងវត្តទឹកថ្លា" ដោយ ហៀន សុវណ្ណមរកត ផ្សាយលើគំណ https://ams.com.kh/khmercivilization/detail/16624 (៧ ធ្នូ ២០២១)។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ដូចបានបញ្ជាក់មកខាងលើ ព្រះវិហារវត្តពេជ្រមកុដមានលំនាំស្ថាបត្យកម្មប្រហាក់ប្រហែលនឹងព្រះវិហារចាស់តូចមួយក្នុងវត្តទឹកថ្លា ដែលស្ថិតនៅតាមបណ្ដោយមហាវិថីសហព័ន្ធរុស្ស៊ី។ ព្រះវិហារវត្តពេជ្រមកុដកសាងពីបេតុងទាំងគ្រឹះ សសរ ផ្ទឹម រួមទាំងដំបូល និងផ្នែកសំខាន់ៗផ្សេងទៀត។ ព្រះវិហារនេះមានទទឹងប្រហែលជាង៧ម៉ែត្រ បណ្ដោយប្រហែល១៤ម៉ែត្រកន្លះ និងកម្ពស់ប្រហែល១០ម៉ែត្រ ហើយសង់នៅលើខឿនកម្ពស់ប្រហែល១ម៉ែត្រ មានទ្វារនិងជណ្ដើរឡើងនៅខាងមុខ២ និងនៅខាងក្រោយ២។ ប៉ុន្តែចំពោះគ្រឿងបង្គុំផ្នែកខាងលើ គេសង្កេតឃើញពុំសូវមានក្បាច់រចនាលម្អទេ ពោលគឺជាព្រះវិហារបំពាក់ជហ្វា៤ (ខាងមុខ២ ខាងក្រោយ២) ហើយផ្ទៃដំបូលជាបេតុងលាត ជ្រាលចុះសងខាង២ថ្នាក់។ នៅតាមចែងដំបូលនីមួយៗ លម្អដោយនាគចែងសណ្ដូកចុះមកផ្នែកខាងចុងចែងដូចព្រះវិហារប្រក់ក្បឿងផ្សេងៗដែរ (រូបលេខ២-៣)។




*រូបលេខ២-៣ លក្ខណៈទូទៅនៃព្រះវិហារវត្តពេជ្រមកុដ*

ការលម្អស្ថាបត្យកម្មផ្នែកខាងលើនៃព្រះវិហារវត្តពេជ្រមកុដ គឺមានតែជហ្វា៤ នាគចែងបាក់បែក១២ និងក្បាច់រចនាលើហោជាងទាំងពីរតែប៉ុណ្ណោះ។ ផ្ទៃហោជាងខាងមុខ និងខាងក្រោយលម្អដោយក្បាច់ភ្ញីទេសដូចគ្នា។ ស្ថិតនៅកណ្ដាលផ្ទៃហោជាងទាំងពីរ គេសង្កេតឃើញមានស្លាកស្នាមរបេះក្បាច់ ឬចម្លាក់ ដែលជាហេតុពិបាកសន្និដ្ឋានជារូបអ្វីប្រាកដ។ ប៉ុន្តែចំពោះហោជាងខាងកើត បើពិនិត្យស្លាកស្នាមរបេះនោះ ទំនងនៅចំណុចកណ្ដាលគេឆ្លាក់រូបព្រះវិស្ណុទ្រង់ឈរកាន់កេតនភណ្ឌ។ ដោយឡែកនៅកណ្ដាលហោជាងខាងលិច គេពិបាកសន្និដ្ឋានជារូបអ្វីឱ្យប្រាកដ (រូបលេខ៤-៥)។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ២៨ ហោជាងខាងកើត



រូបលេខ២៩ ហោជាងខាងលិច

ចំពោះការលម្អស្ថាបត្យកម្មនៅផ្នែកខាងក្រោម នៅតាមក្បាលសសរនីមួយៗជាប់នឹងជញ្ជាំង លម្អដោយក្បាច់ពុម្ពស៊ីម៉ង់ត៍លំនាំដូចសិល្បៈប៉ែកខាងអឺរ៉ុប ដូចគ្នានឹងក្បាលសសរព្រះវិហារវត្តទឹកថ្លាដែរ (រូបលេខ២៦)។ ចំណែកឯសន្ទឹកទ្វារ និងបង្អួចជុំវិញទាំងអស់ពុំមានក្បាច់លម្អអ្វីឡើយ ពោលគឺជាសន្ទឹកក្ដារលាតយ៉ាងសាមញ្ញបំផុត ដែលគេយល់ថាទំនងជួសជុលក្រោយសង្គ្រាម។ ប៉ុន្តែនៅលើផ្ទៃជញ្ជាំងខាងលិច គេឃើញមានគំនូរមួយផ្ទាំងធំដែលរលុបផ្នែកខាងក្រោមដោយអន្ទើ។ ខ្លឹមសារសាច់រឿងក្នុងគំនូរនេះ ប្រហែលនិយាយកាលពីព្រះអង្គនិមន្តប្រោសមាតានៅស្ថានត្រៃត្រិង្ស ដ្បិតនៅផ្នែកខាងលើគេគូរព្រះពុទ្ធអង្គគង់កណ្ដាល ដោយម្ខាងជាពួកទេវតា ព្រះឥន្ទ្រ ព្រះព្រហ្ម ហើយម្ខាងជាស្ត្រីម្នាក់និងបរិវា។ ចំណែកផ្នែកខាងក្រោមដែលរលុបនោះ គឺជាដំណើរព្រះពុទ្ធអង្គនិមន្តចុះតាមជណ្ដើរកែវ (រូបលេខ២៧)។



រូបលេខ២៦ ក្បាច់លម្អក្បាលសសរជុំវិញ



រូបលេខ២៧ គំនូរមួយផ្ទាំងលើជញ្ជាំងខាងលិច

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

គំនូរមួយផ្ទាំងខាងលើនេះប្ញីត្បិតតែរលុបខ្លះ តែមានចំណុចគួរឱ្យពិចារណាបាន បើប្រៀបធៀបនឹងគំនូរតាមវត្តផ្សេងៗក្នុងឃុតដូចគ្នា។ ចំណុចទី១ គំនូរត្រង់នេះបើនៅតាមវត្តខ្លះគេគូរភ្ជាប់គ្នារវាងស្ថានសួគ៌ ស្ថានមនុស្ស និងស្ថាននរក។ ចំណុចទី២ ដែលគួរពិចារណាដែរគឺ ជាងគំនូរគូរព្រះពុទ្ធអង្គលើកព្រះហស្តឆ្វេង ដែលនៅតាមគំនូរវត្តភាគច្រើន តែងឃើញទ្រង់លើព្រះហស្តស្តាំពឡើងហៅថា "សម្តែងធម្មចក្រ"។ ពាក់ព័ន្ធនឹងឃុតដ៏សំខាន់នេះ ក្នុងពុទ្ធប្រវត្តិលើកឡើងថា គ្រាដែលព្រះអង្គនិមន្តប្រោសមាតានោះ គឺមានរយៈពេល៣ខែ មានទេវតាយ៉ាងច្រើនចូលមកស្តាប់។ ពេលនិមន្តត្រឡប់វិញ ព្រះអង្គចុះតាមជណ្តើរកែវដ៏អស្ចារ្យ មានព្រះឥន្ទ្រ និងពពួកទេពនិករដ៏ច្រើនហែហម។ ក្នុងគ្រានោះមានហេតុអស្ចារ្យមួយកើតឡើងគឺ ស្ថានសួគ៌ ស្ថានមនុស្ស និងស្ថាននរកអាចមើលឃើញគ្នាក្នុងពេលតែមួយ។[4]

ផ្នែកខាងក្នុងនៃព្រះវិហារវត្តពេជ្រមកុដ គេសង់ឡើងដោយមានតែល្វែងគ្រឹះនៅកណ្តាល និងអមដោយរបៀងសងខាង តែពុំមានបាំងសាចឡើយ។ លក្ខណៈបែបនេះ គេតែងសង្កេតឃើញដូចគ្នាចំពោះព្រះវិហារបុរាណតូចៗ ជាពិសេសព្រះវិហារជហ្វាបួន ឬសាឡុំជាដើម។ សសរទាំងពីរជួរនៅអមល្វែងគ្រឹះ សុទ្ធសឹងជាសសរបេតុងមូលដែលមានក្បាលសសរលម្អដោយក្បាច់ដូចក្បាលសសរខាងក្រៅដែរ តែដើងសសរគេរចនាជាពងបួនជ្រុង។ នៅលើតួសសរខ្លះ គេគូរលម្អដោយក្បាច់ផ្កាចន្ទន៍ ហើយសសរខ្លះគេគូរលម្អរូបនាគលូនព័ទ្ធជុំវិញ។ ប៉ុន្តែប្រការគួឱ្យកត់សម្គាល់មួយទៀតនៅផ្នែកខាងក្នុងព្រះវិហារខាងលើនេះ គឺរុំស្រោបដោយស្នាមផ្សែងភ្លើងដាសពេញផ្ទៃដំបូលផ្នែកខាងក្រោម ធ្នឹម សសរ និងជញ្ជាំង (រូបលេខ៨)។



រូបលេខ៨ ផ្នែកខាងក្នុងព្រះវិហារ

[4] សាន ផល្លា ២០០៧: ៣១-៣២

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

នៅខាងក្នុងព្រះវិហារនេះដែរ គេសង្កេតឃើញការតម្កល់ព្រះបដិមាហាក់មានលក្ខណៈប្លែកពីព្រះវិហារសព្វថ្ងៃ។ បដិមាទាំងអស់សុទ្ធតែលាបពណ៌មាសឆ្អិនឆ្អៅ។ ស្ថិតនៅចន្លោះល្វែងគ្រឹះត្រង់ចុងខាងលិច គេតម្កល់ព្រះបដិមាព្រះជីវ៍អង្គធំលើបល្ល័ង្កខ្ពស់មួយ អមជុំវិញដោយព្រះបដិមាតូចៗផ្សេងទៀត។ ខាងមុខព្រះបដិមាព្រះជីវ៍ធំ គេតម្កល់ព្រះបដិមាមួយអង្គទៀតនៅក្នុងបុស្បុក រចនាជាកំពូលមុខព្រហ្ម ហើយនៅផ្នែកខាងមុខនោះ គេតម្កល់ព្រះបដិមាទ្រង់ឈរក្នុងកាយវិការព្រះអង្គប្រោសសត្វ ឬអភ័យមុទ្រា (រូបលេខ៩-១១)។ ប៉ុន្តែនៅលើចីវរនៃព្រះបដិមាទ្រង់ឈរនេះ គេរចនាក្បាច់តូចៗលំនាំប្រហាក់ប្រហែលនឹងព្រះពុទ្ធអមិតភៈ(Amitābha) នៃព្រះបដិមាលោកេស្វរសម័យបុរាណ។ ចំពោះអ្នកមានជំនឿមកពីទីជិតឆ្ងាយផ្សេងៗយល់ថា ព្រះបដិមាទាំងអស់ខាងលើមានបុណ្យបារមីក្រៃលែង ដែលនាំឱ្យគេតែងធ្វើដំណើរចូលមកគោរពបូជាស្ទើរពុំលុះថ្ងៃ។



រូបលេខ៩-១១ ការតម្កល់ព្រះបដិមាគោរពបូជាក្នុងព្រះវិហារវត្តពេជ្រមុុដ

ចំណែកឯគំនូរខាងក្នុងព្រះវិហារ គេគូរនៅលើផ្ទៃដំបូលផ្នែកខាងក្រោម និងនៅលើជញ្ជាំងជុំវិញផ្នែកខាងក្នុង។ ប៉ុន្តែសាច់រឿងគំនូរទាំងអស់នោះ គេពិបាកនឹងមើលឃើញណាស់ ដ្បិតរុំស្រោបដោយផ្សែងស្ទើរទាំងស្រុង។ ម្យ៉ាងវិញទៀត គំនូរខ្លះកំពុងរបេះរកជ្រុះដោយអន្ទើៗ។ ប៉ុន្តែយ៉ាងណាក្តី បើពិនិត្យសង្កេតឱ្យជិតដល់ គំនូរក្នុងព្រះវិហារខាងលើ មានបីផ្នែកសំខាន់ៗពាក់ព័ន្ធនឹងរឿងពុទ្ធប្រវត្តិដូចបណ្តាព្រះវិហារផ្សេងៗដែរ។ នៅផ្នែកខាងលើបំផុតត្រង់ក្រោមផ្ទៃដំបូល គេគូរសាច់រឿងទាក់ទងនឹងព្រះពុទ្ធនិមន្តទៅស្ថានសួគ៌ និងរូបទេពនិករផ្សេងៗ។ រីឯនៅលើជញ្ជាំងជុំវិញ គេគូររឿងពុទ្ធប្រវត្តិនៅបន្ទាត់ខាងលើ ដែលរៀបរាប់ចាប់ផ្តើមតាំងពីព្រះអង្គប្រសូត្ររហូតដល់បរិនិព្វាន។ នៅបន្ទាត់ខាងក្រោម គេគូររឿងរ៉ាវផ្សេងៗដកស្រង់ចេញពីជាតក។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ជាសេចក្ដីសង្ខេបមក ព្រះវិហារវត្តពេជ្រមុកុដ គឺជាសំណង់បុរាណតូចមួយដែលមានលំនាំស្ថាបត្យកម្មជាព្រះវិហារជហ្វាបួន ឬអាចនិយាយបានថាមានរាងស្ទើរដូចសាឡុំ ដែលជាសំណង់បណ្ដោះអាសន្នមុនសង់ព្រះវិហារ។ ប៉ុន្ដែចំពោះការតុបតែងព្រះវិហារនេះគេមើលឃើញថាមានលក្ខណៈស្ទើរដូចគ្នាទៅនឹងព្រះវិហារចាស់ក្នុងវត្តទឹកថ្លា ស្ថិតក្នុងរាជធានីភ្នំពេញ ដែលនាំឱ្យគេអាចនិយាយដោយស្មានបានថា ព្រះវិហារវត្តពេជ្រមុកុដសង់ក្នុងរវាងទសវត្សរ៍ទី២០ ឬទសវត្សរ៍ទី៣០។ មិនតែប៉ុណ្ណោះ ចំពោះការរៀបចំខាងក្នុងប្រហែលធ្វើឡើងក្រោយសម័យសង្គ្រាម៕

## ឯកសារយោង

សាន ផល្លា

២០០៧, *គំនូរនៅតាមវត្ត*, វៃឃំ, ភ្នំពេញ

ហៀន សុវណ្ណមរកត

២០២១, "ស្ថាបត្យកម្មបុរាណស្ថិតក្នុងវត្តទឹកថ្លា" ផ្សាយលើគេហទំព័រ https://ams.com.kh/khmercivilization/detail/16624 (៧ ធ្នូ ២០២១)